# ជំពូកទី ១០

## ១០. សន្និដ្ឋាន និង អនុសាសន៍

### *១០.១ សន្និដ្ឋាន*

នាពេលបច្ចុប្បន្ននេះ គំរោងស្ថិតនៅក្នុងដំណាក់កាលសិក្សាពីសមិទ្ធិលទ្ធភាព ហើយដំណាក់កាលរៀបចំប្លង់លំអិត ដំណាក់កាលប្រតិបត្តិការ នឹងត្រូវធ្វើនៅឆ្នាំខាងមុខនេះ (២០០៩-២០១៤)។ កំលាំងអនុភាពតំឡើង ៤០០ MW និងអាចផលិតថាមពលប្រចាំឆ្នាំបាន **១៩៨៣.៩ GWh** ហើយមានតំលៃវិនិយោគសរុបប្រមាណជា **៨៦១ លានដុល្លាអាមេរិក** ហើយគំរោងនេះជាគំរោងប្រភេទ **BOT (សាងសង់ ប្រតិបត្តិការ និងផ្ទេរ)** ដែលមានរយៈ**ពេលប្រតិបត្តិការ ៣០ឆ្នាំ**។

ធានធានធម្មជាតិនៅក្នុងតំបន់គំរោងនាពេលបច្ចុប្បន្ននេះរួមមាន ព្រៃឈើ និងសត្វព្រៃយ៉ាងសំបូរបែប មានខ្យល់ល្អបរិសុទ្ធ និងទឹកទន្លេមានគុណភាពល្អគួរសម ។ តំបន់ព្រៃមួយចំនួនផ្ទុកនូវគុណតំលៃបរិស្ថានយ៉ាងខ្ពស់សំរាប់ជំរកសត្វព្រៃ។ វាគឺជាផ្នែកមួយនៃប្រព័ន្ធអេកូឡូស៊ីព្រៃស្ងួតរបស់ទន្លេមេគង្គក្រោម ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិថា ជាជំរកផ្ទុកសត្វព្រៃដ៏មានតំលៃ ប្រភេទពូជកំរ និង ពូជកំពុងរងគ្រោះថ្នាក់។ម្យ៉ាងវិញទៀត ប្រជាជនដែលរស់នៅក្នុងតំបន់គំរោងភាគច្រើនជាក្រុមជនជាតិភាគតិច ដែលចូលចិត្តរស់នៅជាភូមិតាមដងទន្លេសេសាន និងស្រែពកអស់រយៈកាលយូរយារណាស់មកហើយ។ មិនមានឃើញតំបន់បុរាណសាស្ត្រ ឬ វត្ថុបុរាណ មានវត្តមាននៅក្នុងតំបន់នោះទេ ។ ទោះបីយ៉ាងណាក៏ដោយ មានកន្លែងទឹកធ្លាក់ ឬទឹកជូរពីរបីកន្លែងស្ថិតនៅតំបន់ខ្សែទឹកខាងក្រោមនៃតំបន់គំរោង ដែលមានសក្តានុពលសំរាប់អេកូទេសចរណ៍ផងដែរ។

ក្នុងកំឡុងពេលសាងសង់ និងប្រតិបត្តិរបស់គំរោង ហេតុប៉ះពាល់ជាអវិជ្ជមានគួរអោយកត់សំគាល់មួយចំនួនទៅលើធនធានធម្មជាតិ និងសង្គមនៅក្នុងតំបន់គំរោងនឹងកើតមានឡើង។ ផ្ទៃដីប្រមាណជា ៣៣.០០០ ហ.ត នឹងត្រូវលិចលង់ និងប៉ះពាល់ដោយគំរោង រាប់បញ្ចូលទាំងព្រៃឈើ ដីកសិកម្ម និង ដីលំនៅដ្ឋាន។ គំរោងនឹងប៉ះពាល់សហគមន៍ចំនួន ១០២៥ គ្រួសារ មានប្រជាជន ៤៦២០ នាក់ (ទិន្នន័យឆ្នាំ ២០០៨) រឺ ១៥២៩ គ្រួសារ មានប្រជាជន ៦២២៤ នាក់ (ព្យាករណ៏សំរាប់ ឆ្នាំ ២០១១) ដែលតំរូវឱ្យធ្វើការតាំងលំនៅសារជាថ្មី។ ហេតុប៉ះពាល់ទៅលើរបបជលសាស្ត្ររបស់ទន្លេសេសាននឹងមានកំរិតតិចតួច ដោយសារការរៀបចំប្លង់បញ្ចេញទឹក។ ហេតុប៉ះពាល់ទៅលើវារីសត្វនិងត្រីក្នុងតំបន់មានកំរិតមធ្យម (មានត្រីតែ៤ប្រភេទប៉ុណ្ណោះដែលអាចធ្វើបំលាស់ទីមកពីទន្លេមេគង្គ និងបឹងទន្លេសាប) និង ហេតុប៉ះពាល់ទៅលើសត្វព្រៃមានកំរិតមធ្យម ដោយសារការសាងសង់ទំនប់ និងកិច្ចដំណើរការគំរោង ។ គុណភាពទឹកក្នុងទន្លេសេសាននឹងត្រូវផ្លាស់ប្តូរ ហើយគុណភាពទឹកថយចុះត្រូវបានរំពឹងទុក ជាពិសេសក្នុងពេលសាងសង់ និងអំឡុងពេលពីរបីឆ្នាំនៃកិច្ចប្រតិបត្តិការគំរោងដំបូង។ ធូលី ឧស្ម័ន ក្លិនក្រអូប សំលេងរំខាន និង រំញ័រចេញ ពីសកម្មភាពសាងសង់អាចប៉ះពាល់ដល់សត្វព្រៃ និងសុខភាពមនុស្ស ។ ហេតុប៉ះពាល់ទៅលើ

សុខភាពសាធារណៈ អាចកើតឡើងនៅក្នុងតំបន់សាងសង់ ជំងឺគ្រុនចាញ់ ជំងឺសង្គមដូចជា HIV/AIDS ជំងឺកាមរោគផ្សេងទៀត និង គ្រោះថ្នាក់ចរាចរណ៍ ។ល។ ក៏ដូចជាការសេព និងការធ្វើចរាចរថ្នាំញៀន និងគ្រឿងស្រវឹងផ្សេងៗពីសំណាក់កម្មករឬបុគ្គលិកគំរោងនៅក្នុងសហគមន៍មូលដ្ឋាន ។ ***ផ្អែកតាមលទ្ធផលដែលមានគណនាខាងលើ គេអាចធ្វើការសង្ខេបពីតំលៃធនធានធម្មជាតិដែលនឹងត្រូវបាត់បង់ដោយសារគំរោងក្នុងមួយឆ្នាំគឺ ៤.៥៩៤.១៦០,០០ ដុល្លា*** ។ទោះបីជាយ៉ាងណាក៏ដោយ វិធានការកាត់ បន្ថយបានផ្តល់ជាអនុសាសន៍នៅក្នុង EMP សំរាប់គំរោងអាចកាត់បន្ថយហេតុប៉ះពាល់ទាំងនោះបានមួយចំនួនធំផងដែរ ។ ***តាមការលើកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន (រួមទាំងការទូទាត់ការតាំងទីលំនៅសារជាថ្មី) និង កម្មវិធីត្រួតពិនិត្យតាមដានបរិស្ថានក្រុមហ៊ុននឹងត្រូវចំណាយសរុប ៧៧.៩៩៥.៣២៤,០០ ដុល្លាអាមេរិក ។***

បណ្តុំប៉ះពាល់នឹងកើតឡើងផងដែរនៅកំឡុងពេលសាងសង់ និងក្នុងដំណាក់កាលប្រតិបត្តិ ពីបន្សំរួមគ្នានៃរោងចក្រវារីអគ្គិសនីនៅក្នុងតំបន់រងទឹកភ្លៀងទន្លេសេសាន និង ទន្លេស្រែពក ។ បណ្តុំហេតុប៉ះពាល់រួមមាន ហេតុប៉ះពាល់លើអាកាសធាតុ របបជលសាស្ត្រ ព្រៃឈើ ត្រី និង ជំរកសត្វព្រៃ និងសត្វព្រៃ។ ជាអនុសាសន៍ដ៏ចាំបាច់មួយគឺគ្រប់ក្រុមហ៊ុនថាមពលទាំងអស់ ដែលមានទំនប់វារីអគ្គិសនីនៅក្នុងផ្ទៃរងទឹកភ្លៀងនេះ ត្រូវធ្វើការសំរបសំរួល និងសហការគ្នាក្នុងការគ្រប់គ្រង និង កាត់បន្ថយបណ្តុំហេតុប៉ះពាល់អោយបានច្រើនតាមដែលអាចធ្វើទៅបាន។

ទន្ទឹមនេះគំរោងនឹងផ្តល់ផលប៉ះពាល់ជាវិជ្ជមានដល់ប្រទេសកម្ពុជា ដូចជាការផ្តល់ថាមពលដល់កម្ពុជា និងប្រទេសជិតខាង និងផ្តល់ជាការងារជាច្រើនដល់កម្មករ និងប្រជាជនក្នុងមូលដ្ឋានរហូតដល់រាប់ពាន់នាក់នៅក្នុងដំណាក់កាលសាងសង់ បង្កើនប្រាក់ចំណូលដល់ប្រជាជនមូលដ្ឋានមួយចំនួន ។ ហើយគំរោងនិងធ្វើអោយប្រសើរឡើងនូវសកម្មភាពអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីទ្រទ្រង់កំនើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ។ គំរោងនេះក៏ឆ្លើយតបដោយផ្ទាល់ទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអណត្តិទីបី ដែលចែងថាៈ "ទិដ្ឋភាពសំខាន់បំផុតមួយ នៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល គឺបន្តការអភិវឌ្ឍន៍វិស័យថាមពល ឱ្យឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពទៅនឹងកំនើនតំរូវការសំរាប់អគ្គិសនីដែលមានតំលៃទាប ។ ***ផ្អែកតាមតំលៃលក់ជូនទៅឱ្យអគ្គិសនីកម្ពុជាគឺ 0,0៦២ ដុល្លាក្នុងមួយគីឡូវ៉ាត់ម៉ោង (0.062$/kWh) នោះតំលៃលក់ភ្លើងប្រចាំឆ្នាំគឺ ១២១.១៤១.៨០០,០០ ដុល្លាអាមេរិក*** ។

ហេតុដូចនេះគេអាចសន្និដ្ឋានបានថា នឹងមានហេតុប៉ះពាល់ជាអវិជ្ជមានគួរអោយកត់សំគាល់ទៅលើធនធានបរិស្ថាននិងសង្គម ប៉ុន្តែតាមរយៈការអនុវត្តន៍វិធានការកាត់បន្ថយដែលបានផ្តល់ជាអនុសាសន៍នៅក្នុង EMP នោះហេតុប៉ះពាល់ជាអវិជ្ជមាននឹងបានទូទាត់និងបន្ថយមួយចំនួនធំ ។ គំរោងនឹងនាំមកនូវផលចំណេញយ៉ាងច្រើនដល់សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និង សេដ្ឋកិច្ចតំបន់ តាមរយៈថាមពលអគ្គិសនីយ៉ាងសម្បើម (***១.៩៥៣,៩ លានគីឡូវ៉ាត់ម៉ោង*** ក្នុងមួយឆ្នាំ) និងមានតំលៃទាប (***0.0៦២ គីឡូវ៉ាត់ម៉ោង***) ។

CÔNG TY CỔ PHẦN TƯ VẤN XÂY DỰNG ĐIỆN 1

CÔNG TY CỔ PHẦN EVN QUỐC TẾ

## ១០.២ អនុសាសន៍

តាមការប្រម៉ើលមើលដែលថា គំរោងអាចមានហេតុប៉ះពាល់គួរអោយកត់សំគាល់ ទៅលើធនធានបរិស្ថាន និង ធនធានសង្គមក្នុងតំបន់ នោះអនុសាសន៍មួយចំនួនបានរៀបចំឡើងដូចខាងក្រោម:

- ទំហំអាងស្តុកទឹកត្រូវកាត់បន្ថយអោយបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយនៃផ្ទៃដីដែលនឹងត្រូវលិចលង់ និង បន្ថយគ្រប់ផលវិបាកដែលចេញពីហេតុប៉ះពាល់ទាំងអស់នេះ ។
- ត្រូវផ្តល់អោយបានសមរម្យនូវសំណង និងការតាំងលំនៅសារជាថ្មី ទៅដល់ប្រជាជនដែលនឹងត្រូវរងផលប៉ះពាល់ដោយផ្ទាល់ និង ដោយប្រយោលដោយសារគំរោង ជាពិសេសសំរាប់ភូមិដែលលិចលង់ក្នុងតំបន់អាងស្តុកទឹក និង សំរាប់ភូមិនៅតាមដងទន្លេ ដែលទទួលរងផលលំបាកពីស្តុកត្រីធម្មជាតិដែលថយចុះ ។
- បង្កើតស្ថានីយ៍ភ្ញាស់កូនត្រី និងធ្វើការស្រាវជ្រាវពីវារីសត្វ និង វារីរុក្ខជាតិ និងវិធីសាស្ត្រ ដើម្បីជំនួសការបាត់បង់ត្រី ដោយសារគំរោងវារីអគ្គិសនីនេះ ។
- ត្រូវផ្តល់កម្មវិធីទ្រទ្រង់កសិកម្មដល់សហគមន៍ដែលរងផលប៉ះពាល់ផ្ទាល់និងប្រយោល ក្នុងរយះពេលមួយសមស្របដែលអាចធានាស្ថេរភាពជីវភាពរបស់ពួកគេ ជំនួសការពឹងពាក់លើធនធានធម្មជាតិដែលបាត់បង់ ។
- យ៉ាងហោចណាស់ទឹក ១០០ម$^{3}$/វិនាទី ត្រូវបញ្ចេញឥតដាច់ពីទំនប់នីមួយៗ ក្នុងករណីដែលផ្អាកដំណើរការ ដើម្បីរក្សាប្រព័ន្ធអេកូឡូស៊ី នៅខ្សែទឹកខាងក្រោមអោយនៅមានជីវិត ហើយធារទឹកចេញពីទំនប់ត្រូវពិនិត្យតាមដានជាប់លាប់ ។
- គុណភាពទឹកនៅក្នុងអាងស្តុក និង នៅខ្សែទឹកខាងក្រោមរបស់រចនាសម្ព័ន្ធគំរោងត្រូវពិនិត្យតាមដានអោយបានទៀងទាត់ ហើយចាត់វិធានការអោយបានទាន់ពេលវេលា នៅពេលដែលគុណភាពទឹក មានការបំពុលដែលបង្កដោយទំនប់វារីអគ្គិសនីនេះ ។
- ដើមឈើមានតំលៃនៅក្នុងតំបន់អាងស្តុកទឹកត្រូវបានកាប់ និង យកទៅប្រើវាសំរាប់គោលបំណងផ្សេងទៀត នៅមុនពេលបំពេញទឹកនៅក្នុងអាង។
- កាប់និងដុត មែកឈើ/ស្លឹកឈើ និងឈើតូចៗមួយចំនួន ដោយមានការត្រួតពិនិត្យពីគណៈកម្មការអន្តរក្រសួង ដើម្បីកាត់បន្ថយការបំពុលទឹកក្នុងអាង ។
- មូលនិធិបរិស្ថានប្រចាំឆ្នាំសមស្របមួយគួរត្រូវបានរៀបចំបង់ទៀងទាត់ដល់ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើអោយប្រាកដនូវប្រសិទ្ធិភាព ចំពោះការទូទាត់សង និង ការគ្រប់គ្រងបរិស្ថាន ។
- តំបន់ជំរកសត្វព្រៃសំខាន់ៗដែលនៅសេសសល់ ត្រូវការពារអោយបានជិតដល់តាមដែលអាចធ្វើទៅបាន ។
- តំរូវអោយមានការបោសសំអាតមីននៅកន្លែងសាងសង់ និង ការការដ្ឋានយកថ្មដី ជាពិសេស[illegible]តាំងទីលំនៅសារជាថ្មីរបស់គំរោង ឱ្យបានមុនការអនុវត្តន៍គំរោង។
- គ្រប់វិធានការកាត់បន្ថយ ដែលបានផ្តល់ជាអនុ[illegible] EMP ត្រូវអនុវត្តអោយ[illegible]។

ក្រុមហ៊ុន EVNI មានសំណូមពរដល់ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយបង្កលក្ខណៈងាយស្រួល និងចេញលិខិតអនុញ្ញាតិអោយក្រុមហ៊ុនយើងខ្ញុំ ស្របទៅតាមច្បាប់វិនិយោគ និង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ឱ្យបានទាន់ពេលវេលាដែលបានគ្រោងទុកយ៉ាងពិតប្រាកដ ។

ភ្នំពេញ ថ្ងៃទី 18 ខែ 3 ឆ្នាំ ២០១០

ក្រុមហ៊ុនសិក្សាគំរោង PECC1

**អគ្គនាយក**

CÔNG TY CỔ PHẦN TƯ VẤN XÂY DỰNG ĐIỆN 1

**Le Van Luc**

ភ្នំពេញ ថ្ងៃទី ១៨ ខែ ៣ ឆ្នាំ ២០១០

ក្រុមហ៊ុនរៀបចំរបាយការណ៍ EIA

**អគ្គនាយក**

KEY CONSULTANTS (CAMBODIA) Ltd.

**សោម មិថុនារ័ត្ន**

ភ្នំពេញ ថ្ងៃទី 18 ខែ 3 ឆ្នាំ ២០១០

ក្រុមហ៊ុនវិនិយោគ EVNI

**អគ្គនាយក**

CÔNG TY CỔ PHẦN EVN QUỐC TẾ

**Nguyen Thanh Huan**